**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តបាត់ដំបង**

**សំណុំរឿងព្រហ្មទណ្ឌ**

លេខ: ៤៣៤/២១.០៥.២០១៩

**សំណុំរឿងជំនុំជម្រះ**

លេខ: ១៣៩១/២៧.១១.២០២០

**សាលក្រមព្រហ្មទណ្ឌ(ចាត់របៀប)**

លេខ: ៣៩ (ង)/ ១៣-០១-២០២១

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្ត បាត់ដំបង

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តបាត់ដំបង នាថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០ ដោយមានសមាសភាពជំនុំជម្រះ ដូចតទៅ ៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តបាត់ដំបង

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសវនាការ

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ៤៣៤ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទឈ្មោះ [redacted] ឡា ភេទប្រុស អាយុ ៣៦ឆ្នាំ ជនជាតិខ្មែរ មុខរបរធ្វើស្រែ កាន់សាសនាព្រះពុទ្ធ កើតនៅភូមិខ្វាវ ឃុំ[redacted] ស្រុ[redacted] ខេត្ត[redacted] ទីលំនៅបច្ចុប្បន្នភូ[redacted] ស្រុក [redacted] ឪពុកឈ្មោះ ម៉ា (ស្លាប់) ម្តាយឈ្មោះ[redacted] (ស្លាប់) ប្រពន្ធឈ្មោ[redacted] មានកូនចំនួន ០២នាក់ ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

ដីកាសម្រេចមិនឃុំខ្លួនលេខ ១៣២៧ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរ សាលាដំបូងខេត្តបាត់ដំបង ។

ជាប់ចោទពីបទ **លួច** ប្រព្រឹត្តនៅចំណុចភូ[redacted] ឃុំ[redacted] ស្រុ[redacted] ខេ[redacted] កាលពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៣៥៣** និងមាត្រា **៣៥៦** នៃក្រមព្រហ្មទណ្ឌ ។

ដើមបណ្តឹងឈ្មោះ[redacted] ហឿ ភេទស្រី កើតឆ្នាំ១៩៥៩ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ ទីលំនៅបច្ចុប្បន្នភូមិ[redacted] ស្រុក[redacted] ខេត្ត[redacted] ។

**បានឃើញ** ពាក្យបណ្តឹង ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៩ របស់ឈ្មោះ ចាន់ ហឿ ។

**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ ៣៤០១ ជស.សព ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង ។

**បានឃើញ** ដីកាដំណោះស្រាយលេខ ១២៤៣ ដ.ជ.រ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបាត់ដំបង ។

**បានឃើញ** ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ១០០៥៧ ត.ព្រ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ប្រធានសាលាដំបូងខេត្តបាត់ដំបង ។



ស្កេនជាមួយ CamScanner

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៩ នៅចំណុ[redacted] ឃុំ[redacted] ស្រុក[redacted] ខេត្ត [redacted] មានករណីលួចមួយកើតឡើងបង្កដោយឈ្មោះ[redacted] ឡា និងបក្សពួក បានធ្វើសកម្មភាពលួចដក ដំឡូង របស់ឈ្មោះ ចាន់ ហឿ ភេទស្រី អាយុ ៥៩ឆ្នាំ ហើយនៅពេលឈ្មោះ [redacted] ទូរស័ព្ទទៅប្តឹង សមត្ថកិច្ចឱ្យមកជួយអន្តរាគមន៍ ស្រាប់តែឈ្មោះ[redacted] ឡា និងបក្សពួកនាំគ្នាគេចខ្លួនបាត់ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ[redacted] ឡា បានឆ្លើយថា៖ ខ្លួនមិនទទួលស្គាល់ការចោទប្រកាន់ពីបទលួចនេះទេ។ នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៩ ខ្លួនបាននាំកម្មករទៅកាប់ដើមដំឡូងនៅដីរបស់ឈ្មោះ[redacted] ដែលបានជួលដីដាំដំឡូងរយៈពេល ១ឆ្នាំហើយ (ពីឆ្នាំ២០១៨ដល់ឆ្នាំ២០១៩) ដោយដាំបានមួយដងហើយមុនពេលកើតរឿងហេតុ។ ចំពោះការជួលដីគឺមានធ្វើលិខិតត្រឹមត្រូវ ដោយជួលទំហំ ៤,៥ ហិចតា ជាប់ដីរបស់ខ្លួនចំនួន ០១ហិចតា សរុបទាំងអស់ ៥,៥ ហិចតា ស្ថិតនៅ[redacted] ឃុំ[redacted] ស្រុក [redacted] ខេត្ត[redacted] ដែលជាទីកន្លែងកើតហេតុ។ ខ្លួនពុំបានកាប់ដំឡូងរបស់ឈ្មោះ[redacted] ដើមបណ្តឹងនេះទេ។ ដីរបស់ឈ្មោះ[redacted] គឺនៅឆ្ងាយពីដីខ្លួនប្រហែល ៥០០ ម៉ែត្រ ឯណោះ។ នៅពេលដែលខ្លួន និងកម្មករទាំងអស់ បាននាំគ្នាទៅកាប់ដើមដំឡូងនោះ ស្រាប់តែឈ្មោះ[redacted] (ដើមបណ្តឹង) បានមកឃាត់ខ្លួនមិនឱ្យកាប់ទេ បន្ទាប់មកពួកខ្លួនក៏បាននាំគ្នាត្រលប់មកវិញ។ នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ ២០១៩ ឈ្មោះ[redacted] និងគ្នាគាត់ ៣នាក់ទៀត បានទៅលួចដកដំឡូងនៅលើដីដែលខ្លួនបានជួលពីឈ្មោះ ហែម ហឿ អស់កន្លះហិចតា ហើយអះអាងថាជាដីរបស់ខ្លួនគេទៅវិញ។ ខ្លួនក៏បានប្តឹងទៅសមត្ថកិច្ចដែរ បន្ទាប់មកក៏សមត្ថកិច្ចចុះមកចាប់ឃាត់គាត់ទៅសួរនាំតែម្តង។ ពីមុនកន្លងមកខ្លួនពុំដែលមានទំនាស់អ្វីជាមួយឈ្មោះ[redacted] ទេ បន្ទាប់ពីមានរឿងហេតុកើតឡើង មកដល់ពេលនេះខ្លួនឈប់ដាំដំឡូងលើដីរបស់ឈ្មោះ[redacted]ទៀតហើយ តាំងពីពេលខ្លួនដកដំឡូងរួចក្នុងអំឡុងឆ្នាំ២០១៩ ហើយ ឈ្មោះ[redacted] ក៏បានដាំដំឡូងរបស់គាត់លើដីនោះតែម្តង រហូតដល់សព្វថ្ងៃនេះ។ ម្ចាស់ដីឈ្មោះ[redacted] ភេទប្រុស អាយុ ៦០ឆ្នាំ រស់នៅភ្នំពេញ។ ខ្លួនក៏មានភស្តុតាងដែលជាលិខិតកិច្ចសន្យាជួលដី និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ម្ចាស់ដីជួលមកជាមួយនៅពេលនេះដែរ។ ខ្លួនសំណូមពរតុលាការមេត្តាឱ្យជួយរកយុត្តិធម៌ឱ្យខ្លួនផង ពីព្រោះមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ។

-ដើមបណ្តឹងឈ្មោះ[redacted] ហឿ បានឆ្លើយថា៖ នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៩ ខ្លួនកំពុងតែនៅផ្ទះស្រាប់តែឃើញមនុស្សមួយក្រុមជិះម៉ូតូ និងមានមួយក្រុមទៀតកំពុងតែដើរ សំដៅមកចំការដំឡូងរបស់ខ្លួនស្ថិតនៅ[redacted] ស្រុក[redacted] ខេត្ត[redacted] មានទំហំ ៧,៥ ហិចតា ដែលមានចំងាយ ៥០០ ម៉ែត្រ ពីផ្ទះរបស់ខ្លួន ស្រាប់តែមួយសន្ទុះក្រោយមក មនុស្សមួយក្រុមនោះបាននាំគ្នាដកដំឡូងនៅលើដីរបស់ខ្លួនតែម្តង។ ខ្លួន និងកូនប្រុស បាននាំគ្នាទៅសួរនាំក៏ឃើញឈ្មោះ[redacted] ឡា (ជនជាប់ចោទ) នៅទីនោះ ហើយបានឈ្លោះប្រកែកគ្នា និងបានគំរាមថានឹងសម្លាប់ខ្លួនទៀត។ ខ្លួនក៏បានប្រាប់ថា ក្រុមពួកគាត់បានធ្វើសកម្មភាពបែបនេះច្រើនដងដាក់មកខ្លួន ស្រាប់តែក្រុមឈ្មោះ[redacted] ឡា ខឹងនឹងខ្លួនកាន់តែខ្លាំង។ ពួកខ្លួនក៏បានឈ្លោះគ្នាប្រហែល ១ម៉ោង ខ្លួនក៏ខលទៅប៉ូលីស ដើម្បីមកជួយ ស្រាប់តែក្រុមរបស់ឈ្មោះ ម៉ ឡា បាននាំគ្នាដកដំឡូងនៅលើដីខ្លួនហើយនាំគ្នាយកដំឡូងដាក់ម៉ូតូ និងគោយន្តរបស់ពួកគេជិះចេញទៅបាត់ បន្ទាប់មកនៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៩ ចំការដំឡូងរបស់ខ្លួនដែលមានទំហំ ៧,៥ ហិចតានេះ ត្រូវបានគេកាប់ដើមចោលពេញចំការអស់ប្រហែល ២ ហិចតា។ លុះនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ



ស្កេនជាមួយ CamScanner

២០១៩ ឈ្មោ[redacted] ឡា, ឈ្មោះ[redacted] ខន, ឈ្មោះ[redacted] ហាន, ឈ្មោះ គឹម សាក់, ឈ្មោះ[redacted] ចិន និង មនុស្សមួយក្រុម ប្រហែល ២០ ទៅ ៣០ នាក់ជាង បានយកតាក់ទ័រទៅភ្ជួរបំផ្លិចបំផ្លាញផលដំឡូងអស់ ៧ ហិចតាកន្លះ និងមួយចំនួនទៀត យកធ្វើជាទ្រព្យរបស់ខ្លួន។ បន្ទាប់មកទៀតនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ វេលាម៉ោង ៣ និង ០០ នាទី រសៀល ក្រុមឈ្មោ[redacted] ឡា ដដែល បានរុះរើផ្ទះខ្លួនខ្ទិចខ្ទីថែមទៀត ខណៈ ពេលនោះស្រាប់តែខាងរដ្ឋបាលសាលាស្រុកក៏ខលហៅខ្លួនទៅយកលិខិត តែខ្លួនមិនបានទៅយកទេ ខ្លួន ឱ្យកូនទៅយកជំនួស។ ខ្លួនឃើញក្រុមពួកគេធ្វើសកម្មភាពរុះរើផ្ទះ និងយកទ្រព្យសម្បត្តិរបស់ខ្លួន មាន ពោតចំនួនប្រហែល ៥៣តោន ខ្លួនក៏បានប្ដឹងទៅសមត្ថកិច្ចដែរ តែពួកគាត់មិនហ៊ានទទួលពាក្យបណ្ដឹង របស់ខ្លួនទេ។ ខ្លួនសំណូមពរតុលាការផ្ដន្ទាទោសឈ្មោះ[redacted] ឡា តាមច្បាប់ និងទាមទារសំណងថ្លៃខូច ខាតចំនួន ២០០,០០០ (ពីរសែន) ដុល្លារអាមេរិក និងសំណងជំងឺចិត្ត ១,០០០,០០០ (មួយលាន) ដុល្លារ អាមេរិក។ ដីដាំដំឡូងគឺជាដីរបស់ខ្លួន តែដីនេះមិនទាន់មានប័ណ្ណកម្មសិទ្ធិនៅឡើយទេ មានត្រឹមភូមិឃុំ ប៉ុណ្ណោះ ។

សាក្សីឈ្មោះ[redacted]ធួន បានឆ្លើយថា៖ នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៩ ម៉ោង ៨ និង សូន្យៗ នាទីព្រឹក ខ្លួនឃើញមនុស្សមួយក្រុម ខ្លះជិះម៉ូតូ ខ្លះដើរ សំដៅទៅចំការខាងក្រោយផ្ទះខ្លួន។ ពេលនោះខ្លួន បានដើររកមើលឃើញគេកំពុងនាំគ្នាដកដំឡូងលើដីរបស់ម្ដាយខ្លួនឈ្មោះ[redacted] ពួកគេគឺជាក្រុម របស់ឈ្មោ[redacted]ឡា ពួកក្រុមនេះធ្វើសកម្មភាពដកដំឡូង ដាក់គោយន្តប្រហែល ១ម៉ោង ទើបពួកគេចេញ ទៅ។ មូលហេតុដែលពួកក្រុមរបស[redacted] ឡា ចេញដោយសារម្ដាយខ្លួនបានទៅឃាត់ និងបានខលទៅសមត្ថ កិច្ច ។

សាក្សីឈ្មោ[redacted]សាវុន បានឆ្លើយថា៖ នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៩ ខ្លួន និងកូនបានចូល ទៅលេងផ្ទះដន្លងឈ្មោ[redacted] ហឿ។ ពេលខ្លួនដើរទៅមើលនៅក្រោយផ្ទះ ឃើញមនុស្សមួយក្រុម ខ្លួនមិន ស្គាល់ឈ្មោះទេ កំពុងឈ្លោះប្រកែក និងជេរថានឹងសម្លាប់ឈ្មោ[redacted] ហឿ ទៀត។ មនុស្សមួយក្រុមនេះ គឺមានកាំបិតកាប់ដំឡូង ហើយអ្នកខ្លះដកដំឡូងដោយដៃ យកដាក់គោយន្តដឹកចេញទៅបាត់ ។

សាក្សីឈ្មោ[redacted] នី បានឆ្លើយថា៖ ខ្លួនមិនជាប់សាច់ញាតិជាមួយដើមបណ្ដឹង និងជនជាប់ចោទ ទេ សូមបញ្ជាក់ជូនតុលាការថា ចំពោះដំឡូងនេះគឺឈ្មោ[redacted] ឡា អ្នកដាំ ពីព្រោះឈ្មោះ[redacted] ឡា បានជួល ខ្លួនឱ្យដាំដំឡូងនោះ ហើយដីដែលដាំដំឡូងនោះ គឺឈ្មោ[redacted] ឡា បានជួលគេមក តែពេលទៅដកដំឡូង គឺខ្លួនមិនបានទៅទេ ។

សាក្សីឈ្មោ[redacted]ហាន បានឆ្លើយថា៖ ខ្លួនមិនជាប់សាច់ញាតិជាមួយដើមបណ្ដឹង និងជនជាប់ ចោទទេ សូមបញ្ជាក់ជូនតុលាការថា ចំពោះដំឡូងនេះ គឺឈ្មោ[redacted]ឡា ជាអ្នកដាំ មូលហេតុបានជាខ្លួន បានដឹងពីព្រោះខ្លួនអ្នករស់នៅស្រុកភូមិនឹងស្រាប់ ដីដាំដំឡូងគឺជាដីរបស់ឈ្មោ[redacted] ហឿន បានជួល ឱ្យឈ្មោ[redacted]ឡា អ្នកដាំ ។

សាក្សីឈ្មោ[redacted] ស៊ីម បានឆ្លើយថា៖ ចំពោះដំឡូងគឺឈ្មោ[redacted] ឡា ជាអ្នកទៅទិញដើមដំឡូង ហើយបានជួលគេឱ្យដាំ។ ចម្ងាយពីផ្ទះខ្លួនទៅដីចំការដាំដំឡូង ប្រហែលមួយពាន់ម៉ែត្រជាង។ ខ្លួនលក់ដូរ តាមនឹងបានជាខ្លួនបានដឹងថាឈ្មោ[redacted]ឡា អ្នកដាំ។ ដីដាំដំឡូងខ្លួនដឹងថាឈ្មោ[redacted] ឡា គឺជួលគេមក តែមិនដឹងថាជួលពីអ្នកណាទេ ។



ស្កេនជាមួយ CamScanner

សាក្សីឈ្មោះ[redacted]សាក់ បានឆ្លើយថា៖ ផ្ទះខ្លួន និងផ្ទះរបស់ឈ្មោះ[redacted]ឡា គឺនៅជិតគ្នារំលងផ្ទះមួយ ដីដាំដំឡូងគឺជួលពីឈ្មោះ[redacted]ហឿន មិនដឹងទំហំទេ ដើម្បីដាំដំឡូង ហើយគាត់បានគាស់ដំឡូងអស់ហើយ ។

សាក្សីឈ្មោះ[redacted]ធិន បានឆ្លើយថា៖ ផ្ទះខ្លួនឆ្ងាយពីផ្ទះឈ្មោះ[redacted]ឡា ប្រហែល ២០០ ទៅ ៣០០ ម៉ែត្រ ដំឡូងនឹងគឺឈ្មោះ[redacted]ឡា ជាអ្នកដាំ ពីព្រោះខ្លួនឃ្វាលគោជិតនឹង។ ដីដាំដំឡូងគឺឈ្មោះ[redacted]ឡា គឺ [redacted] ឡា ជួលគេដាំ ។

សាក្សីឈ្មោះ[redacted]គុយ បានឆ្លើយថា៖ ផ្ទះខ្លួន និងផ្ទះឈ្មោះ[redacted]ឡា ប្រហែល ២គីឡូ ដោយសារខ្លួនជាអ្នករស់នៅនឹងយូរឆ្នាំ ទើបដឹងហេតុការណ៍នេះ ដោយឈ្មោះ[redacted]ឡា នេះជាមនុស្សល្អ ហើយដីដាំដំឡូងនេះគឺឈ្មោះ[redacted]ឡា អ្នកដាំ ។

សាក្សីឈ្មោះ[redacted]ស្រីដា បានឆ្លើយថា៖ ផ្ទះខ្លួន ឆ្ងាយពីផ្ទះឈ្មោះ[redacted] ឡា ប្រហែល ១គីឡូ។ ខ្លួនអ្នកស៊ីឈ្នួលដាំដំឡូងតាំងពីថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩ ដំឡូង និងពោត គឺឈ្មោះ[redacted]ឡា អ្នកដាំ ។

សាក្សីឈ្មោះ[redacted]គុញ បានឆ្លើយថា៖ ខ្លួននៅឆ្ងាយពីដីដាំដំឡូងនោះ មិនដឹងរំលងប៉ុន្មានផ្ទះទេ ខ្លួនធ្លាប់ឃើញឈ្មោះ[redacted]ឡា ដាំដំឡូង ហើយដីដាំដំឡូងគឺឈ្មោះ[redacted]ឡា អ្នកដាំ ។

**-តំណាងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង** បានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖ តាមការអង្កេត និងពិនិត្យភស្តុតាងដែលមានក្នុងសំណុំរឿង បញ្ជាក់ឱ្យឃើញថា មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ[redacted]ឡា ភេទប្រុស អាយុ ៣៦ឆ្នាំ ជនជាតិខ្មែរ ពីបទ លួច ប្រព្រឹត្តនៅចំណុចភូ[redacted] ឃុំ[redacted] ស្រុ[redacted] ខេត្ត[redacted] កាលពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។ ដូច្នេះតំណាងអយ្យការបានសម្រេចតម្កល់ដីកាសន្និដ្ឋានស្ថាពរដដែល និងប្តឹងសុំឱ្យផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

*ក្រោយពីបាន :*

ស្តាប់ចម្លើយជនជាប់ចោទ

ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

ស្តាប់ចម្លើយសាក្សី

ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

***ពិនិត្យភស្តុតាងឯកសារនានាមាននៅក្នុងសំណុំរឿង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ :***

## សាលាដំបូងខេត្តបាត់ដំបង

## យល់ឃើញថា

កាលពីថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៩ [redacted] ឃុំ[redacted] ស្រុ[redacted] ខេ[redacted] មានករណី លួច(ដកដំឡូង) ដែលផ្តើមចេញពីទំនាស់គ្នារវាងឈ្មោះ[redacted]ឡា (ជនជាប់ចោទ) និងឈ្មោះ[redacted] ហឿ (ដើមបណ្តឹង) ពីរឿងដំណាំដំឡូងនៅលើដីដែលបានដាំលើទីតាំងកន្លែងកើតហេតុ ហើយភាគីជនជាប់ចោទបានអះអាងថា ដំឡូងដែលខ្លួនបានដកគឺខ្លួនបានដាំលើដីជួល រីឯភាគីដើមបណ្តឹងបានអះអាងថាជារបស់ខ្លួនត្រូវបានឈ្មោះ[redacted]ឡា លួច ដកយក កាលពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ ២០១៩ ហើយក៏មានការកសាងសំណុំរឿងបញ្ជូនតាមនីតិវិធីបន្តមកតុលាការតែម្តង ។

ឆ្លងតាមការសួរដេញដោលនាពេលសវនាការ ឃើញថា អង្គហេតុនៃអំពើ លួច (ដកដំឡូង) នេះកើតឡើង ដោយសារតែការកំណត់ទីតាំងប្រព្រឹត្តបទល្មើស(ទីតាំងដីដាំដំឡូង) ពុំទាន់មានភាពច្បាស់



ស្កេនជាមួយ CamScanner

លាស់ថាជាកម្មសិទ្ធិរបស់ភាគីណាមួយនៅឡើយ ដោយជនជាប់ចោទ មានសាក្សីចូលមកឆ្លើយបំភ្លឺ ស្របជាមួយកិច្ចសន្យាជួលដី បានបញ្ជាក់ថា ដីដាំដំឡូងគឺជនជាប់ចោទបានជួលពីឈ្មោ[redacted]ហឿន ដើម្បីដាំដំឡូង ចំណែកដើមបណ្ដឹង ព្រមទាំងសាក្សីរបស់ខ្លួន ក៏បានបញ្ជាក់ថា ដំឡូងគឺខ្លួនជាអ្នកដាំ ហើយដីដាំដំឡូងក៏ជាកម្មសិទ្ធិរបស់ខ្លួន(ដើមបណ្ដឹង)ផងដែរ ត្រង់ចំណុចនេះ តុលាការយល់ឃើញថា មានភាពខ្វះចន្លោះទាក់ទងនឹងកិច្ចស៊ើបសួរ ពីព្រោះថាពុំបានកោះហៅម្ចាស់ដីជួលឈ្មោ[redacted]ហឿន ដើម្បីមកធ្វើការបញ្ជាក់ពីកម្មសិទ្ធិ(ដីដាំដំឡូង)ម្ចាស់ដីជួលនេះប្រាកដប្រជានៅឡើយ ដូច្នេះគប្បីតុលាការពិចារណាសម្រេចចាត់រៀប ដោយបង្វិលសំណុំរឿងនេះទៅចៅក្រមស៊ើបសួរ ដើម្បីបំពេញកិច្ចស៊ើបសួរបន្ថែមតាមនីតិវិធីច្បាប់ ។

## <u>ហេតុដូច្នេះ</u>

## <u>វិនិច្ឆ័យសេចក្ដី</u>

១. ចាត់របៀបបង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ ៤៣៤ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៩ ទៅចៅក្រមស៊ើបសួរសាលាដំបូងខេត្តបាត់ដំបង បន្ទប់ (គ) ដើម្បីស៊ើបសួរបន្ថែម ដោយធ្វើការកោះហៅឈ្មោ[redacted]ហឿន ភេទប្រុស កើតឆ្នាំ១៩៥៨ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ[redacted] ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៤ មានអាស័យដ្ឋានស្ថិតនៅផ្ទះលេខ[redacted] ផ្លូវលេខ[redacted] សង្កា[redacted] ខណ្ឌ[redacted] រាជធានីភ្នំពេញ ជាអ្នកជួលដីឱ្យជនជាប់ចោទឈ្មោ[redacted] ឡា ភេទប្រុស អាយុ៣៩ឆ្នាំ ថាតើពិតជាបានជួលដីឱ្យជននេះដាំដំណាំដំឡូង ក្នុងអំឡុងពេលកើតហេតុពិតប្រាកដមែនឬយ៉ាងណា ហើយសុំឱ្យបញ្ចេញលិខិតបញ្ជាក់ម្ចាស់ដីជួលជាកម្មសិទ្ធិរបស់ខ្លួនមានឈ្មោ[redacted] ហឿន ដែរទេ ។

២.សាលក្រមនេះបានជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០ និងបានប្រកាសជាសាធារណៈនៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី ។

បើកសិទ្ធិប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**

[redacted]

**ចៅក្រមជំនុំជម្រះ**

[redacted]

ស្កេនជាមួយ CamScanner